**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

**<u>សំណុំរឿងព្រហ្មទណ្ឌ</u>**

**លេខ : ១១៦**

**ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១**

**<u>សាលក្រមព្រហ្មទណ្ឌ</u>**

**លេខ : ៥៥ "គ"**

**ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២**

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង០០នាទីព្រឹក នៅសាលសវនាការទី១ ដោយមានសមាសភាពដូចខាងក្រោម៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង។

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ១១៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] មុំ ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរលក់ដូរ ទីកន្លែងកំណើតនៅ[redacted] ខេត្តកំពង់ចាម និងទីលំនៅមុនពេលឃាត់ខ្លួននៅភូមិស្រែមាន ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងស្នាក់នៅភូមិអង្គ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឈន់ (ស) ម្ដាយឈ្មោះ [redacted] ច្រិប (ស) មេម៉ាយ មានកូនចំនួន០៣នាក់ ប្រវត្តិនៃការផ្ដន្ទាទោសពីតុលាការ គ្មាន ជានីតិជន។ **ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៧៤១/២១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១។**

ជាប់ចោទពីបទ: **ឆបោកប្រាក់, ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅចំណុចភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧, មាត្រា៦២៩ និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ។

-មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វឌ្ឍនា ភេទប្រុស កើតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខងារវេជ្ជបណ្ឌិត (គ្រូពេទ្យ) ទីកន្លែងកំណើតនៅសង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ១៤០ ផ្លូវប្រេត្ត បុរីដីបម៉ុង ៥៩៨ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ សម្បត្តិ ណារិទ្ធិ (រ) ម្តាយឈ្មោះ សំ សុវណ្ណា (រ) នៅលីវ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិ និងផលប្រយោជន៍ឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ប៊ុននាង ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតនៅភូមិស្វាពល ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅភូមិវាលមាស ឃុំវាលវិញ ស្រុកព្រៃនប់ ខេត្តកំពង់សោម ឪពុកឈ្មោះ សំរិត គៀន (ស) ម្តាយឈ្មោះ [redacted] ប៊ុននី (ស) ប្តីឈ្មោះ [redacted] ភក្តី (រ) មានកូនចំនួន ០៣នាក់។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិ និងផលប្រយោជន៍ឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទាន់គ្រឹះស្នា ភេទស្រី កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតនៅភូមិមាយ ឃុំព្រែកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ៥E ផ្លូវលេខ ៤A ភូមិទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សំណាង (រ) ម្តាយឈ្មោះ [redacted] ស៊ុណាត (រ) ប្តីឈ្មោះ [redacted] សេត (រ) មានកូនចំនួន០៥នាក់។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ÷

កាលពីអំឡុងឆ្នាំ២០១៩ នៅចំនុចភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង មានអំពើ ឆបោកប្រាក់ , ក្លែងបន្លំឯកសារសាធារណៈក្លែង និងប្រើប្រាស់ឯកសារសាធារណៈក្លែង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] មុំ ភេទស្រី អាយុ៤២ឆ្នាំ បានលក់ដីទៅឲ្យឈ្មោះ [redacted] ប៊ុននាង, ឈ្មោះ [redacted] ចាន់គ្រឹះស្នា និងឈ្មោះ សម្បត្តិវឌ្ឍនា។ ក្រោយពីបានទទួលប្រាក់គ្រប់ចំនួន ឈ្មោះ [redacted] មុំ និងបក្សពួក ពុំបានរត់ការធ្វើប័ណ្ណកម្មសិទ្ធិឲ្យតាមការសន្យានោះទេ។ ក្រោយពីពិនិត្យឯកសារលក់ទិញរបស់ឈ្មោះ [redacted] មុំ ពីឈ្មោះ [redacted] ទូច មានភាពមិនប្រក្រតី ដោយពុំមានស្នាមមេដៃអ្នកទិញ ហើយក៏ពុំមានការចុះហត្ថលេខាពីលោកមេភូមិ មេឃុំនោះឡើយ។

## នាពេលសាកសួរ

-ជនជាប់ចោទឈ្មោះ [redacted] មុំ បានឆ្លើយថា: ខ្លួនសុំរក្សាចម្លើយដែលបានឆ្លើយនៅដំណាក់កាលអយ្យការ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ទុកជាបានការទាំងស្រុងដដែល ។ ខ្លួនបានទិញដីពីឈ្មោះ [redacted] ទូច ប្រពន្ធឈ្មោះ [redacted] រដ្ឋា ហើយគាត់ថាដីនេះជាដីប្លង់ទន់ ពេលខ្លួនយកទៅលក់ឲ្យដើមបណ្តឹងនោះ ខ្លួនបានអះអាងថាជាប្លង់ទន់ដែរ ខ្លួនបានសន្យាធ្វើប្លង់ឲ្យក្នុងរយៈពេល ០៦ខែ ដោយគិតចាប់ពីថ្ងៃបង់លុយមកឲ្យខ្លួនគ្រប់ចំនួន ក្នុងចំណោម០៣នាក់ ដែលខ្លួនបានលក់ដីឲ្យគាត់នោះ មានម្នាក់ឈ្មោះ [redacted] ប៊ុននាង មិនទាន់ឲ្យលុយខ្លួនគ្រប់ចំនួនទេ នៅខ្វះចំនួន ៣,៧០០ (បីពាន់ប្រាំពីររយ) ដុល្លារអាមេរិក ទៀត។ ខ្លួនលក់ដីទៅឲ្យដើមបណ្តឹងទាំង០៣នាក់នេះ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០។ ក្រោយមកទើបដឹងថា ដីដែលខ្លួនបានលក់ឲ្យទៅដើមបណ្តឹងនេះ មានប្លង់រឹងរួចហើយ តែមិនទាន់បានឲ្យទៅដើមបណ្តឹង។ ខ្លួនមានដីពិត



Scanned with CamScanner

ប្រាកដឱ្យទៅដើមបណ្តឹង គ្រាន់តែមិនទាន់មានឯកសារគ្រប់គ្រាន់ប៉ុណ្ណោះ។ ខ្លួនសូមបដិសេធរាល់ការលើកឡើងរបស់ដើមបណ្តឹង នៅក្នុងពាក្យបណ្តឹងនោះទាំងស្រុង។ ខ្លួនទទួលស្គាល់ថា ពិតជាមិនទាន់មានឯកសារឱ្យទៅដើមបណ្តឹងប្រាកដមែន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់គ្រីះស្នា បានឆ្លើយថា៖ ខ្លួនសុំរក្សាចម្លើយនៅចំពោះមុខអយ្យការ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ទុកជាបានការដដែល។ កាលពីឆ្នាំ២០១៩ ឈ្មោះ [redacted] មុំ បានមកនិយាយបញ្ចុះបញ្ចូលខ្លួន និងម្តាយខ្លួនឱ្យជួយរកគេទិញដី ពេលនោះខ្លួន និងម្តាយបានទិញដីរបស់ឈ្មោះ [redacted] មុំ នៅភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ទំហំ០២ហិចតា ហើយឈ្មោះ [redacted] ប៊ុននាង និងឈ្មោះ [redacted] វឌ្ឍនា ក៏បានទិញដីរបស់ឈ្មោះ [redacted] មុំ នេះដែរ។ ក្នុងការទិញដីនេះ ខ្លួន និងម្តាយមិនបានធ្វើកិច្ចសន្យាទិញលក់ជាលាយលក្ខណ៍អក្សរអ្វីទេ ដោយសារតែរាប់អានគ្នាដូចបងប្អូន ហើយឈ្មោះ [redacted] មុំ ក៏ត្រូវជាកូនធម៌របស់ម្តាយខ្លួនផងដែរ។ ខ្លួនទិញដីនេះ ក្នុង០១ហិចតា តម្លៃ ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ទំហំសរុប ០២ហិចតា តម្លៃ ៤០,០០០ (បួនម៉ឺន) ដុល្លារអាមេរិក។ ប៉ុន្តែដោយឈ្មោះ [redacted] មុំ បានជំពាក់ប្រាក់របស់ម្តាយខ្លួនខ្លះ និងបានកាត់កងគ្នាជាមួយម្តាយរបស់ខ្លួន ខ្លួនត្រូវប្រគល់ប្រាក់ទៅឱ្យឈ្មោះ [redacted] មុំ តែចំនួន ២៦,៥០០ (ពីម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ប៉ុណ្ណោះ។ ដីនេះ ខ្លួន និងម្តាយបានប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] មុំ ចំនួន ០៥លើក ស្មើនឹងចំនួន ២៦,៥០០ (ពីម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ។ ចំពោះការប្រគល់ការប្រាក់ គឺធ្វើឡើងដោយផ្ទាល់ដៃ និងបានថតរូបភាពទុកផងដែរ។ ក្នុងការទិញលក់នេះ ឈ្មោះ [redacted] មុំ ថាមិនចាំបាច់ធ្វើប្លង់អ្វីទេ ចាំយកតែចំណេញទៅ។ ដោយសារតែពុំឃើញមានអ្នកទិញពីមួយខែ ទៅមួយខែដូចបានសន្យារកម៉ូយដាក់នោះ ខ្លួន និងម្តាយ បានឱ្យឈ្មោះ [redacted] មុំ ធ្វើប្លង់កាត់ឈ្មោះ ត្រឹមស្រុកមកឱ្យខ្លួនវិញ គាត់សន្យាធ្វើឱ្យខ្លួន។ ពេលខ្លួនទារប្លង់ត្រឹមស្រុកនោះ គាត់ថាធ្វើប្លង់ត្រឹមភូមិទៅ។ ខ្លួន និងម្តាយមិនទទួលយកប្លង់ត្រឹមភូមិនោះទេ ព្រោះបាននិយាយគ្នាថា យកប្លង់ត្រឹមស្រុក និងនិយាយថា រត់ប្លង់ឱ្យ ហើយឱ្យខ្លួន និងម្តាយទៅផ្តិតមេដៃលើក្រសាសស តែខ្លួន និងម្តាយមិនព្រមផ្តិតមេដៃទេ មានតែឈ្មោះ [redacted] ប៊ុននាង និងឈ្មោះ [redacted] វ-ឌ្ឍនា ទេ ដែលបានផ្តិតមេដៃ។ ឈ្មោះ [redacted] មុំ និយាយថា គាត់ឱ្យផ្តិតមេដៃលើក្រសាសសនេះ ព្រោះម្ចាស់ដីដើមធ្វើឱ្យបាត់ប្លង់ ទាមទារឱ្យធ្វើទុតិយតា។ ឈ្មោះ [redacted] មុំ បាននិយាយសុទ្ធតែមិនពិតទាំងអស់ គាត់លក់ដីមកឱ្យខ្លួន និងម្តាយ បែរជាមិនមានដីឱ្យខ្លួន និងម្តាយទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុននាង បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] មុំ តាំងពីឆ្នាំ២០១៩ តាមរយៈមិត្តភក្តិឈ្មោះ [redacted] ចាន់គ្រីះស្នា។ កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៩ ខ្លួនបានទិញដី០១កន្លែងពីឈ្មោះ [redacted] មុំ នៅភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង តម្លៃ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ក្នុង០១ហិចតាកន្លះ។ ខ្លួនបានប្រគល់លុយ ០៤ដំណាក់កាល លើកទី១ ចំនួន ១៨,០០០ (មួយម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក, លើកទី២ចំនួន ៤,០០០ (បួនពាន់) ដុល្លារអាមេរិក, លើកទី៣ ចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក និងលើកទី៤ចំនួន ១,៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក សរុបចំនួន២៦,៥០០ (ពីរម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក។ គាត់បានហៅខ្លួនទៅធ្វើប្លង់ដែរ តែធ្វើមិនបានសម្រេចដោយមិនដឹងពីមូលហេតុអី។ បន្ទាប់មកឈ្មោះ ឈន់ មុំ ចេះតែកុហក និងគេចវេសមិនព្រមចូលមកដោះស្រាយរហូតដល់បច្ចុប្បន្ន។ ឈ្មោះ [redacted] មុំ បាននិយាយថា បើអញមានគំនិតអាក្រក់ អញមិនធ្វើប្លង់



Scanned with CamScanner

ឲ្យក៏មិនដឹងធ្វើអីអញ្ចេរ។ ខ្លួនមានភស្តុតាងបញ្ជាក់ដែលឈ្មោះ[redacted]មុំ បានទទួលប្រាក់ពីខ្លួនចំនួន០៤លើក។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វឌ្ឍនា បានឆ្លើយថា៖ ខ្លួនសុំរក្សាចម្លើយ ដូចដែលបានឆ្លើយនៅចំពោះមុខតំណាងអយ្យការ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ទុកជាបានការទាំងស្រុងដដែល។ ខ្លួនបានទិញដីឈ្មោះ ឈន់ មុំ នៅខែវិច្ឆិកា ឆ្នាំ២០១៩ ជាមួយឈ្មោះ[redacted] ចាន់គ្រឹះស្នា និងឈ្មោះ [redacted] ប៊ុននាង។ ដំបូងឡើយខ្លួនមានបំណងទិញដីទំហំ០១ហិចតា ហើយឲ្យលុយទំហំតែកន្លះហិចតាសិន ក្នុងតម្លៃ ១២,៥០០ (មួយម៉ឺនពីរពាន់ប្រាំរយ) ដុល្លារអាមេរិកនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ដោយផ្ទាល់ដៃ មិនបានធ្វើកិច្ចសន្យាអ្វីទេ គ្រាន់តែបានថតរូបគាត់រាប់លុយ និងអង្គុយជុំគ្នាប៉ុណ្ណោះ។ រំលងបាន០៣ខែ ខ្លួនបានឲ្យឈ្មោះ[redacted] មុំ ធ្វើកិច្ចសន្យាលក់ផ្តាច់ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ទំហំដីកន្លះហិចតា មូលហេតុខ្លួនយកតែកន្លះហិចតា ព្រោះខ្លួនមិនទុកចិត្តឈ្មោះ[redacted] មុំ ដោយហេតុថា ខ្លួនចូលភាគហ៊ុនរកស៊ីជាមួយគាត់ ខ្លួនបានដាក់ប្រាក់ចំនួន ១,៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក ដើម្បីទិញដីមួយកន្លែងទៀត គាត់ប្រាប់ថាកក់ភ្លាម លក់ភ្លាម ចែកគ្នាភ្លាម ប៉ុន្តែពេលលក់បានប្រាក់ចំណេញចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិក ក្នុងម្នាក់ៗគាត់មិនឲ្យ ហើយយកលុយនោះទៅកក់ដីនៅកន្លែងផ្សេងទៀត។ ឈ្មោះ [redacted] មុំ ឲ្យខ្លួនថែមប្រាក់ចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក ទៀត តែខ្លួនមិនព្រម។ ដោយឈ្មោះ [redacted] មុំ ប្រាប់មកពួកខ្លួនថាឲ្យធ្វើសំបុត្របញ្ជាក់កំណើត បញ្ជាក់ភាពនៅលីវ និងអត្តសញ្ញាណប័ណ្ណ ហើយឲ្យយកឯកសារទាំងនេះ ទៅជួបគ្នានៅភូមិបាល ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង គេធ្វើប្លង់រឹងឲ្យតែម្តង។ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ពួកខ្លួនទាំងអស់គ្នា បានទៅជួបជុំគ្នានៅសុរិយាដី ពេលនោះឈ្មោះ [redacted] មុំ បានឲ្យខ្លួនផ្តិតមេដៃលើទម្រង់ឯកសារដែលមិនទាន់បានបំពេញអក្សរ ទុកជូនសុរិយាដីជាមួយឈ្មោះ [redacted] ប៊ុននាង ដោយឈ្មោះ[redacted] មុំ បានប្រាប់ថាយ៉ាងម៉េចទេ មានតែឈ្មោះ[redacted] ចាន់គ្រឹះស្នា និងម្តាយគាត់ប៉ុណ្ណោះ បានសួរដេញដោលឈ្មោះ ឈន់ មុំ ទើបឈ្មោះនេះថា ម្ចាស់ដីដើមធ្វើឲ្យបាត់ប្លង់ ផ្តិតធ្វើប្លង់ថ្មី។ ខ្លួនសូមបញ្ជាក់ថា ឈ្មោះ [redacted] មុំ ប្រមូលយកឯកសារពីពួកខ្លួនទៅធ្វើប្លង់មានច្រើនដងហើយ មិនដឹងថា គាត់យកឯកសារនេះទៅប្រើប្រាស់យ៉ាងណាខ្លះទេ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ និងផលប្រយោជន៍ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]-វឌ្ឍនា បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានពិនិត្យសំណុំរឿង ជនជាប់ចោទទិញដីពីឈ្មោះ [redacted] ទូច ពិនិត្យឯកសារមិនសមស្រប មិនបានដឹងថាដីអ្វី ហេតុអ្វីបានជាគេមិនផ្ទេរឲ្យគាត់ជាក់ស្តែង ដូច្នេះបញ្ជាក់ថាដីដែលគាត់លក់មិនទាន់ថាជាដីរបស់គាត់ទេ ព្រោះគាត់ពុំទទួលសិទ្ធិពីម្ចាស់ដីដើម។ ម្យ៉ាងទៀតគាត់ទទួលលុយពីឆ្នាំ២០១៩មកម្ល៉េះ នៅពេលសួរគាត់ គាត់សន្យាថាថ្ងៃនេះ ថ្ងៃនោះ ឲ្យធ្វើលិខិតបញ្ជាក់ផ្សេងៗ ប៉ុន្តែមិនដឹងយកទៅធ្វើអ្វី។ ជនជាប់ចោទសន្យាថា០៣ខែទេ នឹងកាត់ប្លង់បាន ប៉ុន្តែរយៈពេល២ឆ្នាំមកហើយ គាត់ព្យាយាមគេចវេសរហូត។ យោងតាមអង្គហេតុ និងឯកសារក្នុងសំណុំរឿង ខ្ញុំបាទសូមស្នើសុំទៅលោកតុលាការមេត្តាផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ និងសូមទាមទារប្រាក់ចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក មកវិញ និងទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាជាប្រាក់ចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។

-លោក [redacted] ជាមេធាវីការពារសិទ្ធិ និងផលប្រយោជន៍ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុននាង បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ឆ្លងកាត់ការសួរដេញដោល និងពិនិត្យសំណុំរឿង ខ្ញុំបាទសូមធ្វើសេចក្តីសន្និដ្ឋានថា

កាលពីឆ្នាំ២០១៩ កូនក្ដីខ្លួនបានទិញដីចំនួន ០១កន្លែង តម្លៃ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ដោយឱ្យប្រាក់ជាបួនដំណាក់កាល គឺលើកទី១ ចំនួន ១៨,០០០ (មួយម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក, លើកទី២ចំនួន ៤,០០០ (បួនពាន់) ដុល្លារអាមេរិក, លើកទី៣ ចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក និងលើកទី៤ចំនួន ១,៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក សរុបចំនួន២៦,៥០០ (ពីរម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក។ ក្រោយពីបានទិញដី កូនក្ដីខ្ញុំបាទបានទៅផ្ដិតមេដៃនៅសុរិយោដី ប៉ុន្តែចេះតែធ្វើមិនបានសម្រេចដោយមិនដឹងពីមូលហេតុអី។ បន្ទាប់មកឈ្មោះ ឈន់ មុំ ចេះតែកុហកនិងគេចវេសមិនព្រមចូលមកដោះស្រាយរហូតដល់បច្ចុប្បន្ន។ ឈ្មោះ [redacted] មុំ បាននិយាយទៅកូនក្ដីខ្ញុំបាទថា បើអញមានគំនិតអាក្រក់ អញមិនធ្វើប្លង់ឱ្យក៏មិនដឹងធ្វើអីអញដែរ។ ដូច្នេះយោងតាមអង្គហេតុ និងឯកសារក្នុងសំណុំរឿង ខ្ញុំបាទសូមស្នើសុំទៅតុលាការមេត្តាផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់ និងទាមទារប្រាក់របស់កូនក្ដីខ្លួនមកវិញ និងទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៣៥,០០០ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការនាពេលនេះ តំណាងអយ្យការមិនមានអ្វីសន្និដ្ឋានក្រៅពីតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ៨៦១ ដសត/២០២១ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ ទុកជាបានការដដែល និងស្នើសុំឱ្យតុលាការមេត្តាពិនិត្យ និងសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ អវត្តមាន។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ក្រោយពីបានពិនិត្យសំណុំរឿង និងសួរដេញដោលនាពេលសវនាការនេះ ឃើញថា កូនក្ដីខ្ញុំបាទមានភាពល្ងង់ខ្លៅ ដោយសារគាត់ទុកចិត្តគ្នា គាត់ថា ទំហំ ០៧ហិចតា មិនទាន់មានប្លង់រឹងទេ ប៉ុន្តែភូមិឃុំថាមានប្លង់រឹង ដោយសារដឹងហេតុនេះ ក៏គាត់មកធ្វើប្លង់រឹងវិញ ប៉ុន្តែដោយសារកូវីដ ទើបយូរបែបនេះ។ ចំពោះឯកសារដែលថា កូនក្ដីខ្ញុំបាទក្លែងឯកសារនោះពុំមានភស្តុតាងណាមួយបញ្ជាក់ថាក្លែងនោះទេ។ ដូច្នេះសូមសំណូមពរទៅតុលាការលើកលែងបទចោទ ដោយសារតែការធ្វើឯកសារយឺតយ៉ាវ។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ អវត្តមាន។

-ជនជាប់ចោទឈ្មោះ [redacted] មុំ បាននិយាយសំដីចុងក្រោយថា សូមតុលាការមេត្តាដោះលែងនាងខ្ញុំវិញ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយ និងអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធ និងផលប្រយោជន៍ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាក្នុងក្រុមប្រឹក្សាជំនុំជម្រះ



Scanned with CamScanner

-ក្រោយពីបានពិនិត្យ និងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់រួចហើយ។

**យល់ឃើញថា ÷**

១-ជនជាប់ចោទឈ្មោះ [redacted] មុំ ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ៖ **ឆបោកប្រាក់, ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅចំណុចភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧, មាត្រា៣៧៨ មាត្រា៦២៩ និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ។

២-ជនជាប់ចោទឈ្មោះ [redacted] មុំ បានឆ្លើយថា ខ្លួនសុំរក្សាចម្លើយដែលបានឆ្លើយនៅដំណាក់កាលអយ្យការ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ទុកជាបានការទាំងស្រុងដដែល ។ ខ្លួនបានទិញដីពីឈ្មោះ [redacted] ទូច ប្រពន្ធឈ្មោះ [redacted] រង្គា ហើយគាត់ថាដីនេះជាដីប្លង់ទន់ ពេលខ្លួនយកទៅលក់ឱ្យដើមបណ្តឹងនោះ ខ្លួនបានអះអាងថាជាប្លង់ទន់ដែរ ខ្លួនបានសន្យាធ្វើប្លង់ឱ្យក្នុងរយៈពេល ០៦ខែ ដោយគិតចាប់ពីថ្ងៃបង់លុយមកឱ្យខ្លួនគ្រប់ចំនួន ក្នុងចំណោម០៣នាក់ ដែលខ្លួនបានលក់ដីឱ្យគាត់នោះ មានម្នាក់ឈ្មោះ [redacted] ប៊ុននាង មិនទាន់ឱ្យលុយខ្លួនគ្រប់ចំនួនទេ នៅខ្វះចំនួន ៣,៧០០ (បីពាន់ប្រាំពីររយ) ដុល្លារអាមេរិក ទៀត។ ខ្លួនលក់ដីទៅឱ្យដើមបណ្តឹងទាំង០៣នាក់នេះ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០។ ក្រោយមកទើបដឹងថា ដីដែលខ្លួនបានលក់ឱ្យទៅដើមបណ្តឹងនេះ មានប្លង់រឹងរួចហើយ តែមិនទាន់បានឱ្យទៅដើមបណ្តឹង។ ខ្លួនមានដីពិតប្រាកដឱ្យទៅដើមបណ្តឹង គ្រាន់តែមិនទាន់មានឯកសារគ្រប់គ្រាន់ប៉ុណ្ណោះ។ ខ្លួនសូមបដិសេធរាល់ការលើកឡើងរបស់ដើមបណ្តឹង នៅក្នុងពាក្យបណ្តឹងនោះទាំងស្រុង។ ខ្លួនទទួលស្គាល់ថា ពិតជាមិនទាន់មានឯកសារឱ្យទៅដើមបណ្តឹងប្រាកដមែន។ ចម្លើយនេះ គប្បីតុលាការទទួលមកពិចារណា។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់គ្រីះស្នា បានឆ្លើយថា ខ្លួនសុំរក្សាចម្លើយនៅចំពោះមុខអយ្យការ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ទុកជាបានការដដែល។ កាលពីឆ្នាំ២០១៩ ឈ្មោះ [redacted] មុំ បានមកនិយាយបញ្ចុះបញ្ចូលខ្លួន និងម្តាយខ្លួនឱ្យជួយរកគេទិញដី ពេលនោះខ្លួន និងម្តាយបានទិញដីរបស់ឈ្មោះ [redacted] មុំ នៅភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ទំហំ០២ហិចតា ហើយឈ្មោះ [redacted] ប៊ុននាង និងឈ្មោះ [redacted] វណ្ណរ៉ា ក៏បានទិញដីរបស់ឈ្មោះ [redacted] មុំ នេះដែរ។ ក្នុងការទិញដីនេះ ខ្លួន និងម្តាយមិនបានធ្វើកិច្ចសន្យាទិញលក់ជាលាយលក្ខណ៍អក្សរអ្វីទេ ដោយសារតែរាប់អានគ្នាដូចបងប្អូន ហើយឈ្មោះ [redacted] មុំ ក៏ត្រូវជាកូនធម៌របស់ម្តាយខ្លួនផងដែរ។ ខ្លួនទិញដីនេះ ក្នុង០១ហិចតា តម្លៃ ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ទំហំសរុប ០២ហិចតា តម្លៃ ៤០,០០០ (បួនម៉ឺន) ដុល្លារអាមេរិក។ ប៉ុន្តែដោយឈ្មោះ [redacted] មុំ បានជំពាក់ប្រាក់របស់ម្តាយខ្លួនខ្លះ និងបានកាត់កងគ្នាជាមួយម្តាយរបស់ខ្លួន ខ្លួនត្រូវប្រគល់ប្រាក់ទៅឱ្យឈ្មោះ [redacted] មុំ តែចំនួន ២៦,៥០០ (ពីម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ប៉ុណ្ណោះ។ ដីនេះ ខ្លួន និងម្តាយបានប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] មុំ ចំនួន ០៥លើក ស្មើនឹងចំនួន ២៦,៥០០ (ពីម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ។ ចំពោះការប្រគល់ការប្រាក់ គឺធ្វើឡើងដោយផ្ទាល់ដៃ និងបានថតរូបភាពទុកផងដែរ។ ក្នុងការទិញលក់នេះ ឈ្មោះ [redacted] មុំ ថាមិនចាំបាច់ធ្វើប្លង់អ្វីទេ ចាំយកតែចំណេញទៅ។ ដោយសារតែពុំឃើញមានអ្នកទិញពីមួយខែ ទៅមួយខែដូចបានសន្យារកម៉ូយដាក់នោះ ខ្លួន និងម្តាយ បានឱ្យឈ្មោះ [redacted] មុំ ធ្វើប្លង់កាត់ឈ្មោះ ត្រឹមស្រុកមកឱ្យខ្លួនវិញ គាត់សន្យាធ្វើឱ្យខ្លួន។ ពេលខ្លួនទារប្លង់ត្រឹមស្រុកនោះ គាត់ថាធ្វើប្លង់ត្រឹមភូមិទៅ។ ខ្លួន និងម្តាយមិនទទួល

យកប្លង់ត្រឹមភូមិនោះទេ ព្រោះបាននិយាយគ្នាថា យកប្លង់ត្រឹមស្រុក និងនិយាយថា រត់ប្លង់ឲ្យ ហើយឲ្យខ្លួន និងម្ដាយទៅផ្ដិតមេដៃលើក្រសាសស តែខ្លួន និងម្ដាយមិនព្រមផ្ដិតមេដៃទេ មានតែឈ្មោះ [redacted] ប៊ុននាង និងឈ្មោះ [redacted] ឌ្ឍនា ទេ ដែលបានផ្ដិតមេដៃ។ ឈ្មោះ [redacted] មុំ និយាយថា គាត់ឲ្យផ្ដិតមេដៃលើក្រសាសសនេះ ព្រោះម្ចាស់ដីដើមធ្វើឲ្យបាត់ប្លង់ ទាមទារឱ្យធ្វើទុតិយតា។ ឈ្មោះ [redacted] មុំ បាននិយាយសុទ្ធតែមិនពិតទាំងអស់ គាត់លក់ដីមកឲ្យខ្លួន និងម្ដាយបែរជាមិនមានដីឲ្យខ្លួន និងម្ដាយទេ។ ចម្លើយនេះ គប្បីតុលាការពិចារណា។

៤-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុននាង បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] មុំ តាំងពីឆ្នាំ២០១៩ តាមរយៈមិត្តភក្តិឈ្មោះ [redacted]ចាន់គ្រឹះស្នា។ កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៩ ខ្លួនបានទិញដី០១កន្លែងពីឈ្មោះ [redacted] មុំ នៅភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង តម្លៃ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ក្នុង០១ហិចតាកន្លះ។ ខ្លួនបានប្រគល់លុយ ០៤ដំណាក់កាល លើកទី១ ចំនួន ១៨,០០០ (មួយម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក, លើកទី២ចំនួន ៤,០០០ (បួនពាន់) ដុល្លារអាមេរិក, លើកទី៣ ចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក និងលើកទី៤ចំនួន ១,៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក សរុបចំនួន២៦,៥០០ (ពីរម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក។ គាត់បានហៅខ្លួនទៅធ្វើប្លង់ដែរ តែធ្វើមិនបានសម្រេចដោយមិនដឹងពីមូលហេតុអី។ បន្ទាប់មកឈ្មោះ [redacted] មុំ ចេះតែកុហក និងគេចវេសមិនព្រមចូលមកដោះស្រាយរហូតដល់បច្ចុប្បន្ន។ ឈ្មោះ [redacted] មុំ បាននិយាតថា បើអញមានគំនិតអាក្រក់ អញមិនធ្វើប្លង់ឲ្យក៏មិនដឹងធ្វើអីអញដែរ។ ខ្លួនមានភស្តុតាងបញ្ជាក់ដែលឈ្មោះ [redacted] មុំ បានទទួលប្រាក់ពីខ្លួនចំនួន០៤លើក។ ចម្លើយនេះ គប្បីតុលាការពិចារណា។

៥-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វឌ្ឍនា បានឆ្លើយថា៖ ខ្លួនសុំរក្សាចម្លើយ ដូចដែលបានឆ្លើយនៅចំពោះមុខតំណាងអយ្យការ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ទុកជាបានការទាំងស្រុងដដែល។ ខ្លួនបានទិញដីឈ្មោះ ឈន់ មុំ នៅខែវិច្ឆិកា ឆ្នាំ២០១៩ ជាមួយឈ្មោះ [redacted] ចាន់គ្រឹះស្នា និងឈ្មោះ [redacted] ប៊ុននាង។ ដំបូងឡើយ ខ្លួនមានបំណងទិញដីទំហំ០១ហិចតា ហើយឲ្យលុយទំហំតែកន្លះហិចតាសិន ក្នុងតម្លៃ ១២,៥០០ (មួយម៉ឺនពីរពាន់ប្រាំរយ) ដុល្លារអាមេរិក នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ដោយផ្ទាល់ដៃ មិនបានធ្វើកិច្ចសន្យាអ្វីទេ គ្រាន់តែបានថតរូបគាត់រាប់លុយ និងអង្គុយជុំគ្នាប៉ុណ្ណោះ។ រំលងបាន០៣ខែ ខ្លួនបានឲ្យឈ្មោះ [redacted] មុំ ធ្វើកិច្ចសន្យាលក់ផ្ដាច់ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ទំហំដីកន្លះហិចតា មូលហេតុខ្លួនយកតែកន្លះហិចតា ព្រោះខ្លួនមិនទុកចិត្តឈ្មោះ [redacted] មុំ ដោយហេតុថា ខ្លួនចូលភាគហ៊ុនរកស៊ីជាមួយគាត់ ខ្លួនបានដាក់ប្រាក់ចំនួន ១,៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក ដើម្បីទិញដីមួយកន្លែងទៀត គាត់ប្រាប់ថាកក់ភ្លាម លក់ភ្លាម ចែកគ្នាភ្លាម ប៉ុន្តែពេលលក់បានប្រាក់ចំណេញចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិក ក្នុងម្នាក់ៗគាត់មិនឲ្យ ហើយយកលុយនោះទៅកក់ដីនៅកន្លែងផ្សេងទៀត។ ឈ្មោះ ឈន់ មុំ ឲ្យខ្លួនថែមប្រាក់ចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក ទៀត តែខ្លួនមិនព្រម។ ដោយឈ្មោះ [redacted] មុំ ប្រាប់មកពួកខ្លួនថា ឲ្យធ្វើសំបុត្របញ្ជាក់កំណើត , បញ្ជាក់ភាពនៅលីវ និងអត្តសញ្ញាណប័ណ្ណ ហើយឲ្យយកឯកសារទាំងនេះ ទៅជួបគ្នានៅភូមិបាល ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង គេធ្វើប្លង់រឹងឲ្យតែម្ដង។ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ពួកខ្លួនទាំងអស់គ្នា បានទៅជួបជុំគ្នានៅសុរិយោដី ពេលនោះឈ្មោះ [redacted] មុំ បានឲ្យខ្លួនផ្ដិតមេដៃលើទម្រង់ឯកសារដែលមិនទាន់បានបំពេញអក្សរ ទុកជូនសុរិយោដីជាមួយឈ្មោះ [redacted] ប៊ុននាង ដោយឈ្មោះ [redacted] មុំ បានប្រាប់ថាយ៉ាងម៉េចទេ មានតែឈ្មោះ [redacted] ចាន់គ្រឹះ

ស្នា និងម្ដាយគាត់ប៉ុណ្ណោះ បានសួរដេញដោលឈ្មោះ [redacted] មុំ ទើបឈ្មោះនេះថា ម្ចាស់ដីដើមធ្វើឱ្យបាត់ប្លង់ ផ្តិតធ្វើប្លង់ថ្មី។ ខ្លួនសូមបញ្ជាក់ថា ឈ្មោះ [redacted] មុំ ប្រមូលយកឯកសារពីពួកខ្លួនទៅធ្វើប្លង់មានច្រើនដងហើយ មិនដឹងថា គាត់យកឯកសារនេះទៅប្រើប្រាស់យ៉ាងណាខ្លះទេ។ ចម្លើយនេះ គប្បីតុលាការពិចារណា។

៦-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការនាពេលនេះ តំណាងអយ្យការមិនមានអ្វីសន្និដ្ឋានក្រៅពីតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ៨៦១ ដសព/២០២១ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ ទុកជាបានការដដែល និងស្នើសុំឱ្យតុលាការមេត្តាពិនិត្យ និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

៧-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, របាយការណ៍ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ , បទចោទប្រកាន់របស់តំណាងអយ្យការ និងភស្តុតាងនានានៅក្នុងសំណុំរឿង ឃើញថា កាលពីអំឡុងឆ្នាំ២០១៩ នៅចំណុចភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ពិតជាមានអំពើ **ឆបោកប្រាក់, ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] មុំ ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដែលអំពើនេះ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧, មាត្រា៣៧៨, មាត្រា៦២៩ និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] មុំ ដែលបានបញ្ចុះបញ្ចូលឱ្យឈ្មោះ [redacted] ចាន់គ្រឹះស្នា, ឈ្មោះ [redacted] វឌ្ឍនា និងឈ្មោះ [redacted] ប៊ុននាង ឱ្យទិញដីខ្លួន និងដាក់ភាគហ៊ុនមួយចំនួន និងបានបង្គាប់ឱ្យដើមបណ្តឹង (អ្នកទិញ) ប្រគល់ប្រាក់មកឱ្យខ្លួនជាច្រើន ហើយសន្យាថា រត់ឯកសារ និងប្រគល់ដីឱ្យដើមបណ្តឹង តែក្រោយពីបានទទួលប្រាក់មួយចំនួនធំរួចហើយ ជនជាប់ចោទ មិនបានបំពេញលក្ខខណ្ឌដែលបានសន្យា ចំពោះកិច្ចសន្យាលក់ផ្តាច់រវាងឈ្មោះ ឈន់ មុំ និងដើមបណ្តឹង (អ្នកទិញ) ធ្វើឡើងពុំសមស្របនេះបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] មុំ ពិតជាមានចេតនាទុច្ចរិតនៃអំពើប្រព្រឹត្តតាំងពីដំបូង។

៩-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] មុំ ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ពីបទ៖ **ឆបោកប្រាក់, ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅចំណុចភូភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧, មាត្រា៣៧៨ មាត្រា៦២៩ និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វឌ្ឍនា ទាមទារប្រាក់ដើមចំនួន ១,៤000 (មួយម៉ឺនបួនពាន់) ដុល្លារ-អាមេរិក និងទាមទារសំណងជម្ងឺចិត្តចំនួន ៣0,000 (បីម៉ឺន) ដុល្លារអាមេរិក។ ការទាមទារនេះ គប្បីតុលាការពិចារណា។

១១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់គ្រឹះស្នា ទាមទារប្រាក់ដែលបាត់បង់ចំនួន ២៦.៥00 (ពីរម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក។ ការទាមទារនេះ គប្បីតុលាការពិចារណា។

១២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុននាង ទាមទារប្រាក់ដែលបាត់បង់ចំនួន ៣៥.000 (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។ ការទាមទារនេះ គប្បីតុលាការពិចារណា។



Scanned with CamScanner

# ហេតុដូច្នេះតុលាការ

# វិនិច្ឆ័យសេចក្តី

១/- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] មុំ ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៥ (ប្រាំ) ឆ្នាំ ពីបទ **ឆបោកប្រាក់, ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅចំណុចភូមិជ្រេស ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្ត-កំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧, មាត្រា៣៧៨ មាត្រា៦២៩ និងមាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ។

២/- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] មុំ សងប្រាក់ដែលបាត់បង់ជាប្រាក់ចំនួន ១,៤០០០ (មួយម៉ឺនបួនពាន់) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១០,០០០,០០០ (ដប់លាន) រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]វឌ្ឍនា។ ការទាមទារលើសពីនេះត្រូវច្រានចោល។

៣/- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] មុំ សងប្រាក់ដែលបាត់បង់ចំនួន ២៦.៥០០ (ពីរម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់គ្រីះស្នា។ ការទាមទារលើសពីនេះត្រូវច្រានចោល។

៤/- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] មុំ សងប្រាក់ដែលបាត់បង់ចំនួន ២៦.៥០០ (ពីរម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុននាង។ ការទាមទារលើសពីនេះត្រូវច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មុំ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វឌ្ឍនា, ឈ្មោះ [redacted] ចាន់គ្រីះស្នា និងឈ្មោះ [redacted] ប៊ុននាង។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ១៤រោច ខែអាសាឍ ឆ្នាំខាល
ចត្វាស័ក ព.ស ២៥៦៦
កំពង់ឆ្នាំង, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| (ហត្ថលេខា និងត្រា) | (ហត្ថលេខា និងត្រា) | (ហត្ថលេខា និងត្រា) | (ហត្ថលេខា និងត្រា) |

[redacted]

---

បានសម្រង់ចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១៤រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
កំពង់ឆ្នាំង, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២
ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]